# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៤៩/១៣-អ៊ីធើនីធី ក្លូប៊ល ស្ព័តធីង (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល
(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ីង សុទ្ធី**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន អ៊ីធើនីធី ក្លូប៊ល ស្ព័តធីង (ខេមបូឌា)**

អាសយដ្ឋាន ៖ ភូមិដំណាក់អំពិល ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល

ទូរស័ព្ទ ៖ ០៩៧ ៨៧៦ ៣ ៦៦៦ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក ឡុង ប៉ាង | តំណាង GMAC |
| ២- លោក ហេង មេសា | តំណាងក្រុមហ៊ុន |
| ៣- លោក នៅ ទិត្ថា | អ្នកសង្កេតការណ៍ |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះលេខ ១៦ A ផ្លូវ៣៦០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៩៣៥ ៤៩៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក វី សិទ្ធីណែត — មន្ត្រីសម្របសម្រួលវិវាទការងារសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

២- អ្នកស្រី យ៉ុង លាភ — មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-ស្នើសុំលុយបាយថ្ងៃត្រង់ចំនួន ១៣ ដុល្លារ សម្រាប់កម្មករ ។

២-ពេលកម្មករទៅបន្ទប់ទឹក មិនឱ្យក្រុមហ៊ុនកត់លេខកាត ។

៣-ស្នើមិនឱ្យក្រុមហ៊ុនបង្ខំកម្មករធ្វើការថែមម៉ោង ។

៤-ស្នើមិនឱ្យក្រុមហ៊ុនផ្លាស់ប្តូរកម្មករស្រេចតែចិត្ត ។

៥-ស្នើឱ្យកម្មករមានប្រាក់ខែស្មើគ្នា ការងារដូចគ្នា ។

៦-ស្នើឱ្យក្រុមហ៊ុនបន្ថែមម៉ាស៊ីនស្លែនមេដៃ៣បន្ថែម ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១២៧/១៣ កប/កណ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលបានទទួលពាក្យ

បណ្ដឹងរបស់សហជីពសេរីកម្មករ ស្ដីពីកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកែលម្អលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្ដឹងនេះមក មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាលបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារ នេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាលើកចុងក្រោយនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាទេ។

ចំណុចមិនសះជាចំនួន ០៦ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមលេខ ១២៧/១៣ ក.ប/កណ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣។

ដោយសារតែកម្មករនិយោជិតបានធ្វើកូដកម្ម ចាប់តាំងពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ មក ហើយក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលដំណឹងពីភាគីទាំងពីរថា កូដកម្មនៅតែបន្តនៅក្រុមហ៊ុន អ៊ីធើនីធី ក្លូបិល ស្ព័តធីង (ខេមបូឌា) ដដែល បើទោះបីជាសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏ដោយ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានសម្រេចចេញសេចក្ដីបញ្ជាលេខ ០០៩/១៣ កបអ. ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន អ៊ីធើនីធី ក្លូបិល ស្ព័តធីង (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្ដាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីសៀលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ តទៅតាមវេនរបស់ខ្លួន។ ក្រោយពីទទួលបានសេចក្ដីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមក កូដករបានត្រឡប់ចូលធ្វើការវិញ នៅថ្ងៃទី០១ និងទី០២ ខែមីនា ឆ្នាំ២០១៣។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានសម្រេចបើកសវនាការ នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៣ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរបានចូលរួមសវនាការ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលតាមពេលវេលាកំណត់។ ប៉ុន្តែ នៅមុនពេលចាប់ផ្ដើមសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ចាប់ពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ មក កម្មករនិយោជិតបានបន្តធ្វើកូដកម្មវិញ រហូតមកដល់ថ្ងៃសវនាការនេះ។

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

- លិខិតរបស់ក្រុមហ៊ុន អ៊ីធើនីធី ក្លូបិល ស្ព័តធីង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល សំណើសុំចេញសេចក្ដីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន អ៊ីធើនីធី ក្លូបិល ស្ព័តធីង។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

១- របាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អ៊ីធើនីធី ក្លូបិល ស្ព័តធីង លេខ ១២៧/១៣ កប/កណ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣។

THE ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន អ៊ីធើនីធី ក្លូបិល ស្ព័តធីង ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល

១- លិខិតអញ្ជើញសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាមកជ្រើសរើសអាជ្ញាកណ្ដាល លេខ ២២៣ កប/អក/វក/លកអ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្ដាលចេញពីបញ្ជីសហជីពកម្មករនិយោជិត ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣។

៣- សេចក្ដីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០០៩/១៣ កបអ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៤៦ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ ។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៤៧ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ ។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្ដីសម្រេច ៖**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្ដាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចែងថា ៖ *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្ដាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា៣១៨ នៃច្បាប់ស្ដីពីការងារ)ឬវិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះ ត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្ដាលបានអញ្ជើញឱ្យចូលរួម"*។

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងមិនបន្តដំណើរការអាជ្ញាកណ្ដាលទេ នៅពេលណាភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្ដីជូនដំណឹងនេះ កំណត់ថា ៖

*"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្ដីបង្គាប់លើវិវាទការងាររួមនេះ*

*បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម "។*

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រែគ្ខ អង្គរ,សាន់វេ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

*" ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ " ។*

*" ចំណុចទី ១១ - ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ " ។*

នៅក្នុងសំណុំរឿងលេខ ៧៧/០៦-ហ្វ្រង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេសិនរ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។ ក្នុងករណីនេះ ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម និងមិនព្រមគោរពតាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ៤៩/១៣- អ៊ីធើនីធី ក្លូបិល ស្ព័តធីង (ខេមបូឌា) ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា ៖ ------------------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អេន ណាន**

ហត្ថលេខា ៖ ---------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ---------------------------------------